# សុន្ទរកថា

## ថ្លែងដោយ បណ្ឌិត ហារុហ៊ីសា ហាន់ដា (Haruhisa Handa)

### ប្រធានមូលនិធិអន្តរជាតិដើម្បីសិល្បៈ និង វប្បធម៌ នៃទីក្រុងតូក្យូ-ប្រទេសជប៉ុន

### ក្នុងពិធីប្រគល់ “ជ័យលាភីអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ”

### ជូនសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស

### សាលសន្និសីទ ចតុមុខ ព្រឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧

**សូមគោរព**

**សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**សូមគោរព គណៈអធិបតី ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ជាទីគោរព !**

**១-** ជាបឋម ក្នុងនាមអង្គការ World Mate និង សាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទ សូមសម្តែងនូវអំណរគុណដ៏ខ្ពង់ខ្ពស់ និង សូមស្វាគមន៍ដោយស្មោះចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចនាយករដ្ឋមន្ត្រី** ដែលបានអញ្ជើញចូលរួមជាប្រធានគណៈអធិបតី ក្នុងពិធីប្រគល់ជ័យលាភី « **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ** »ដ៏មហោឡារិកនេះ ។

**២-** **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ** គឺជាអាហាររូបកណ៍ថ្នាក់បរិញ្ញាប័ត្រ ទ្រង់ទ្រាយធំមួយ នៅសាកលវិទ្យាល័យកម្ពុជា សំរាប់ឆ្នាំសិក្សា ២០០៧ - ២០១០ ដែលឧបត្ថម្ភដោយអង្គការ World Mate ដែលជាអង្គការរបស់ខ្ញុំបាទផ្ទាល់ ។ អាហារូបករណ៍នេះ គឺជាអាហារូបករណ៍ពេញថ្លៃចំនួន ៥០០ កន្លែង សម្រាប់ចែកជូនដល់សិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ។ នេះគឺជាលើកទី១ និង ជាប្រវត្តិសាស្ត្រដែលអង្គការរបស់ខ្ញុំ បានឧបត្ថម្ភមូលនិធិដ៏ច្រើនបំផុតសំរាប់ផ្តល់ជាអាហារូបករណ៍ និស្សិតថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា ដោយខ្ញុំបាទចាត់ទុកថា ប្រទេសកម្ពុជាគឺជា

មាតុភូមិទី២របស់ខ្ញុំ ហើយខ្ញុំចង់អោយយុវជនជំនាន់ក្រោយ បានឆ្លងកាត់ឧត្តមសិក្សាគ្រប់ៗគ្នា ដើម្បីក្លាយខ្លួនជាបញ្ញវន្តបន្តវេន សំរាប់កសាង និង អភិវឌ្ឍប្រទេសជាតិ អោយបានរុងរឿងទៅអនាគត ។

៣- អង្គការ World Mate និង សាកលវិទ្យាល័យកម្ពុជា សូមថ្លែងនូវសេចក្តីដឹងគុណដ៏ខ្ពង់ខ្ពស់ ចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** ដែលបានអនុញ្ញាតអោយប្រសិទ្ធិនាមអាហារូបករន៍នេះថា « **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ** » ។ នេះ គឺជាមហាករុណាទិគុណរបស់ **សម្តេចនាយក** ដែលយើងខ្ញុំ ពុំអាចបំភ្លេចបាន ។

៤- **សម្តេចនាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ** ជាទីគោរព !

គោលដៅជាសក្តានុពល នៃការបង្កើតអោយមាន **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ** គឺដើម្បី :

- **មួយ:** ចូលរួមអភិវឌ្ឍធនធានមនុស្ស ពិសេសគឺធនធានបញ្ញវន្ត នៅប្រទេសកម្ពុជា បន្ទាប់ពីធនធាននេះត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង នៅក្នុងសម័យខ្មែរក្រហម ប្រល័យពូជសាសន៍ ពីឆ្នាំ១៩៧៥-១៩៧៩ ;
- **ពីរ:** លើកស្ទួយវិស័យអប់រំថ្នាក់ឧត្តមសិក្សា និង ការអភិវឌ្ឍសមត្ថភាព និង ធនធាន **(Human Capital)** ដើម្បីជួយអោយប្រទេសកម្ពុជា អាចឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងចរន្ត នៃ សាកលភាវូបនីយកម្ម និង ការធ្វើសមាហរណកម្មដ៏ពេញលេញទៅក្នុងតំបន់ និង សហគមន៍អន្តរ ជាតិ ។
- **បី:** អប់រំហ្វឹកហ្វឺន និង ស្ថាបនាអ្នកដឹកនាំវ័យក្មេង ទៅអនាគត ;
- **បួន:** ផ្តល់ឱកាសអប់រំ និង ការសិក្សាកាន់តែច្រើនឡើងថែមទៀតជូននិស្សិតក្រីក្រ ដែលមកពីជនបទអោយបានបន្តការសិក្សានៅថ្នាក់ឧត្តម ;
- **ប្រាំ:** រួមចំណែកកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា តាមរយៈការលើកស្ទួយចំណេះដឹង ចំណេះធ្វើមនសិការវិជ្ជាជីវៈ និង ការស្វែងរកការងារ ក៏ដូចជាការជួយអភិវឌ្ឍសង្គមបញ្ញវន្តខ្មែរមួយ ដែលមានសមត្ថភាព គុណភាព និង ប្រសិទ្ធភាពបំពេញការងារ ដើម្បីបុព្វហេតុអភិវឌ្ឍន៍ជាចិរភាពនៅប្រទេសកម្ពុជា ។

៥-	អង្គការ World Mate និង សាកលវិទ្យាល័យកម្ពុជា សូមសរសើរដល់សិស្សានុសិស្សទាំងអស់ ដែលបានខិតខំចូលរួមប្រលងប្រជែងរហូតដល់ទទួលបានជ័យលាភី និង សូមខិតខំយកចិត្តទុកដាក់ខិតខំរៀនសូត្រអោយបានជោគជ័យ ។

ម្យ៉ាងទៀត សូមអភ័យទោសចំពោះសិស្សានុសិស្សដែលប្រឡងធ្លាក់ ពុំអាចបានទទួលរង្វាន់ជ័យលាភីនេះបាន ។ សង្ឃឹមថា តាមរយៈការខិតខំព្យាយាមសិក្សាបន្តទៀត ក្មួយៗគង់នឹងទទួលបានអាហារូបករណ៍សាកលវិទ្យាល័យកម្ពុជា ច្រើនទៀត នៅលើកក្រោយ ។

៦-	សារជាថ្មីម្តងទៀត នៅទីបញ្ចប់នេះ ក្នុងអង្គការ World Mate និង សាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទ សូមសម្តែងនូវសេចក្តីដឹងគុណដោយស្មោះចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** ដែលបានចំណាយពេលដ៏មានតម្លៃអញ្ជើញចូលរួមជា **ប្រធានគណៈអធិបតីដ៏ខ្ពង់ខ្ពស់** ក្នុងពិធីប្រគល់ជ័យលាភីអាហារូបបករណ៍ នេះ ។

សូមគោរពជូនពរ **សម្តេចនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ** និង **អន្តរជាតិ** សូមអោយបានប្រកបដោយជោគជ័យ សេរីមង្គល និង វិបុលសុខ គ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**